The following is an abridged translation of a sermon by John Piper. If you wish to read the original English, please go to the link below.

http://www.desiringgod.org/sermons/do-not-forsake-your-mothers-teaching

## ស៊េរី៖ ការចិញ្ចឹមបីបាច់ថែរក្សា និងការបង្រៀនកូនៗឲ្យសង្ឃឹមលើជ័យជម្នះរបស់ព្រះជាម្ចាស់

## សុភាសិត ១:៧-៩

កណ្ឌគម្ពីរ សុភាសិត ចាប់ផ្ដើមដំបូងគឺ «នេះជាសុភាសិតរបស់សាឡូម៉ូន ជាព្រះរាជបុត្រានៃដាវីឌអ៊ីស្រាអែល ស្ដេចសាសន៍អ៊ីស្រាអែល»។ ស្ដេចសាឡូម៉ូនជាស្ដេចដ៏អស្ចារ្យមួយអង្គ ហើយក៏ជាបុត្រារបស់ស្ដេចដ៏អស្ចារ្យមួយអង្គដែរ។ នោះមានន័យថា ទ្រង់មានព្រះកិត្តិនាមល្បីល្បាញ មានអំណាចខ្លាំងក្លា ហើយខ្ពង់ខ្ពស់ឧត្តុង្គឧត្តមក្នុងអាណាចក្ររបស់ទ្រង់ទៀតផង។ មនុស្សគ្រប់រូបក្រាបចុះថ្វាយបង្គំនៅចំពោះព្រះវត្តមានទ្រង់។ ពួកគេគោរពតាមគ្រប់ព្រះរាជបញ្ជារបស់ទ្រង់។ ទ្រង់មានពេញដោយអំណាច និងកិត្តិយស។

### សូម្បីតែស្ដេចដ៏អស្ចារ្យក៏គួរឱនគោរពព្រះមាតាដែរ

តើស្ដេច សាឡូម៉ូន បានប្រព្រឹត្តយ៉ាងដូចម្ដេចចំពោះព្រះមាតាទ្រង់ ទោះបើទ្រង់ជាស្ដេចដ៏អស្ចារ្យក៏ដោយ? ព្រះមាតាទ្រង់មានព្រះនាមថា បាតសេបា។ មាតាទ្រង់បានរៀបអភិសេកជាមួយបិតាទ្រង់គឺព្រះបាទ ដាវីឌ ក្នុងកាលៈទេសៈដែលព្រះជាម្ចាស់មិនសព្វព្រះហឫទ័យ។ ទោះជាយ៉ាងនេះក៏ដោយ ក៏បាតសេបានៅតែជាព្រះមាតាទ្រង់ដដែល។ កណ្ឌគម្ពីរ ១របាក្សត្រ ២:១៩ បានចែងថា៖

«ដូច្នេះ បាតសេបាក៏ចូលទៅគាល់ស្ដេចសាឡូម៉ូនដើម្បីទូលទ្រង់ឲ្យអ័ដូនីយ៉ា ឯស្ដេចទ្រង់តើនឡើងទទួលក៏ឱនព្រះអង្គគោរព រួចគង់លើបល្ល័ង្កទ្រង់វិញ ហើយបង្គាប់ឲ្យគេយកបល្ល័ង្ក១មកដាក់ថ្វាយមាតាទ្រង់ ព្រះនាងក៏គង់ខាងស្តាំទ្រង់»។

បន្ទាប់មកទ្រង់និងមាតាទ្រង់ក៏ចាប់ផ្ដើមជជែកគ្នា។ ស្ដេច សាឡូម៉ូន បានក្រោកឡើងទទួលមាតាទ្រង់ ថែមទាំងឱនព្រះកាយគោរពព្រះមាតា ហើយចេញព្រះរាជបញ្ជាឲ្យសេនាយកបល្ល័ង្កមួយមកដាក់ថ្វាយមាតាទ្រង់សម្រាប់ការជជែកគ្នាទៀតផង។ បាតសេបាជាមាតាទ្រង់។ ទោះបើ បុគ្គលនោះមានឋានៈជាស្ដេចក៏គួរឱនព្រះកាយគោរពព្រះមាតាដែរ ពេលណាដែលព្រះមាតាចូលគាល់។

ស្ដេច សាឡូម៉ូន មិនមែនជាស្ដេចដ៏គ្រប់លក្ខណ៍នោះទេ។ ហើយទ្រង់ក៏មិនមែនជាបុរសដ៏គ្រប់លក្ខណ៍នោះដែរ។ មនុស្សដែលព្រះជាម្ចាស់បានប្រើឲ្យនិពន្ធព្រះគម្ពីរក៏មិនមែនជាមនុស្សគ្រប់លក្ខណ៍ដែរ។ ប៉ុន្តែព្រះជាម្ចាស់បានប្រទានឲ្យស្ដេចសាឡូម៉ូនមានប្រាជ្ញា ហើយទ្រង់បានរក្សាពាក្យដ៏ពិតមួយចំនួនរបស់ស្ដេចសាឡូម៉ូនទុកសម្រាប់យើងដែលមានក្នុងកណ្ឌ

គម្ពីរ សុភាសិត។ ពេលនេះ ខ្ញុំចង់យើងទាំងអស់គ្នាស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមរយៈស្តេច សាឡូម៉ូន។

**ប្រាំមួយមេរៀន៖ ព្រះជាម្ចាស់សំខាន់ជាងគេ**

នៅក្នុងកណ្ឌគម្ពីរ សុភាសិត ១:៧-៩ ស្តេច សាឡូម៉ូន បានរៀបរាប់ប្រាប់យើងពីសេចក្តីបង្រៀនប្រាំមួយយ៉ាងដែលទាក់ទងនឹងព្រះជាម្ចាស់ទាំងស្រុង។ មេរៀនទាំងនោះមិនខុសប្លែកពីប្រាជ្ញារបស់លោកីយ៍ទាំងស្រុងទេ។ ប៉ុន្តែដោយសារការផ្តល់មតិយោបល់របស់លោកីយ៍មិនបានបញ្ចូលព្រះវត្តមាននៃការប្រឹក្សារបស់ព្រះជាម្ចាស់ ការនោះច្បាស់ជានឹងនាំឲ្យយើងមានគ្រោះថ្នាក់ធំជាមិនខាន។ ស្តេច សាឡូម៉ូន សព្វព្រះទ័យឲ្យយើងស្តាប់ព្រះតម្រិះរបស់ទ្រង់ ព្រោះព្រះតម្រិះទាំងនោះជាប់ទាក់ទងនឹងព្រះជាម្ចាស់។

ជារឿយៗ យើងតែងតែគិតថា កណ្ឌគម្ពីរ សុភាសិត គឺគ្រាន់តែជាសៀវភៅមួយក្បាលដែលបង្រៀនយើងពីជីវិតរស់នៅប្រចាំថ្ងៃនៅលើផែនដីនេះប៉ុណ្ណោះ។ ជាការពិតណាស់! កណ្ឌគម្ពីរ សុភាសិត ពិតជាបង្រៀនយ៉ាងដូច្នោះមែន ប៉ុន្តែចំណុចស្នូលនៃមេរៀនក្នុងកណ្ឌគម្ពីរនេះគឺ ការយកព្រះជាម្ចាស់ជាចម្បង ពីព្រោះមេរៀននេះទាក់ទងនឹងទ្រង់។

ឧទាហរណ៍៖ សុភាសិត ៣០:៨-៩ បានចែងថា៖

«...សូមកំចាត់សេចក្តីភូតភរ និងពាក្យកុហកឲ្យឆ្ងាយពីទូលបង្គំទៅ ហើយសូមកុំឲ្យទូលបង្គំមានសេចក្តីទាល់ក្រ ឬជាអ្នកមានដែរ សូមគ្រាន់តែចិញ្ចឹមទូលបង្គំដោយអាហារដែលត្រូវការប៉ុណ្ណោះ ក្រែងទូលបង្គំបានឆ្អែត ហើយបោះបង់ចោលទ្រង់ដោយពាក្យថា ព្រះយេហូវ៉ាជាអ្នកណាហ្ន៏ ឬក្រែងទូលបង្គំមានសេចក្តីទាល់ក្រ ហើយទៅជាលួចគេ ព្រមទាំងប្រើព្រះនាមនៃព្រះជាទីមើលងាយផង»។

តើលោកអ្នកឃើញពីអ្វីដែលខគម្ពីរទាំងពីរនេះរៀបរាប់ពីព្រះជាម្ចាស់ឬទេ? បុរសដែលពេញដោយប្រាជ្ញាបានអធិស្ឋានដូច្នេះថា «សូមកុំឲ្យទូលបង្គំមានសេចក្តីទាល់ក្រ ឬជាអ្នកមានដែរ»។ ហេតុអ្វី? ពីព្រោះបើទូលបង្គំមានពេក នោះទូលបង្គំនឹងពោលថា «ព្រះយេហូវ៉ាជាអ្នកណាហ្ន៏!» ហើយប្រសិនបើទូលបង្គំទាល់ក្រពេក នោះទូលបង្គំប្រហែលជានឹងធ្វើជាចោរលួចគេហើយក៏មិនដឹង។ ហេតុអ្វីបានជាការនេះអាក្រក់ម្ល៉េះ? តើដោយសារតែលោកអ្នកអាចនឹងត្រូវប៉ូលីសចាប់ដាក់គុកឬ? ឬក៏លោកអ្នកខ្លាចបាត់បង់កេរ្តិ៍ឈ្មោះ? ទេ! មិនមែនមកពីមូលហេតុទាំងនេះទេ។ អ្នកប្រាជ្ញបានលើកឡើងថា ពីព្រោះបើខ្ញុំក្លាយជាចោរ នោះខ្ញុំនឹង «ប្រើព្រះនាមនៃព្រះ ជាទីមើលងាយ»។

ការមានបានវាគ្រោះថ្នាក់ណាស់ ពីព្រោះនៅចុងបំផុតអ្វីដែលសំខាន់ជាងគេគឺ ព្រះជាម្ចាស់។ ហើយការទាល់ក្រក៏ជាការគ្រោះថ្នាក់ដែរ ពីព្រោះនៅចុងបំផុតអ្វីដែលសំខាន់ជាងគេគឺ ព្រះជាម្ចាស់។ ព្រះជាម្ចាស់បាននិពន្ធកណ្ឌគម្ពីរ សុភាសិត (កណ្ឌនេះមានជាប់ទាក់ទងនឹងជីវិតរស់នៅប្រចាំថ្ងៃរបស់យើងជាងគេ) ដើម្បីថ្វាយសិរីល្អដល់ទ្រង់ និងដើម្បីការពារយើង

មិនឲ្យបោះបង់ព្រះជាម្ចាស់ចោលពេលយើងក្លាយជាអ្នកមាន ឬក៏ប្រើព្រះនាមនៃព្រះជាទីមើលងាយពេលដែលយើងទាល់ក្រនោះដែរ។

មេរៀនទាំងប្រាំមួយក្នុងកណ្ឌគម្ពីរ សុភាសិត ១:៧-៩ ទាក់ទងនឹងព្រះជាម្ចាស់ ហើយមេរៀនទាំងនោះក៏ជាប់ទាក់ទងនឹងជីវិតរស់នៅប្រចាំថ្ងៃរបស់យើងដែរ។

## ១. ដើមកំណើតគ្រួសារ

ព្រះជាម្ចាស់គឺជាអង្គដែលបានផ្តួចផ្តើមព្រះតម្រិះក្នុងការបង្កើតក្រុមគ្រួសារ។

ឪពុកម្តាយ និងកូនៗមានទំនាក់ទំនងដ៏ពិសេសក្នុងការមើលខុសត្រូវគ្នាទៅវិញទៅមក។ កណ្ឌគម្ពីរ សុភាសិត ១:៨ បានថែងថា «នែ កូនអើយ ចូរស្តាប់ពាក្យប្រៀនប្រដៅរបស់ឪពុកចុះ កុំឲ្យកូនបោះបង់ចោលសេចក្តីដំបូន្មានរបស់ម្តាយឯងឡើយ»។ ទាំងស្តេច សាឡូម៉ូន ទាំងយើងភាគច្រើនធ្លាប់បានឯកភាពនឹងខគម្ពីរនេះ ប៉ុន្តែឥឡូវនេះ យើងមិនអាចសន្មតថា គ្រប់គ្នាឯកភាពនឹងខគម្ពីរនេះទៀតទេ។ ការបង្កើតឲ្យមានគ្រួសារគឺជាព្រះតម្រិះរបស់ព្រះជាម្ចាស់ ជាផែនការ និងជារបៀបរបស់ទ្រង់។ ព្រះជាម្ចាស់បានតាក់តែងឲ្យមានគ្រួសារតាំងពីទ្រង់បង្កើតផ្ទៃមេឃនិងផែនដីមកម្ល៉េះ។

កណ្ឌគម្ពីរ លោកុប្បត្តិ ១:២៧-២៨ ដែលនោះជាជំពូកដំបូងនៃកណ្ឌទីមួយក្នុងព្រះគម្ពីរទាំងមូលបានថែងថាៈ

«ទ្រង់ក៏បង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឲ្យចំនឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេឡើងជាប្រុសជាស្រី ទ្រង់ប្រទានពរដល់គេ ហើយមានបន្ទូលថា ចូរបង្កើតកូនឲ្យចំរើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដីចុះ...»។

តើឲ្យពួកគេបង្កើតកូន «ឲ្យមានពេញពាសលើផែនដី» បានយ៉ាងដូចម្តេច? តើដោយការរួមដំណេកមិនរើសមុខឬ? កណ្ឌគម្ពីរ លោកុប្បត្តិ ២:២៤ បានផ្តល់ចម្លើយថា «ដោយហេតុនោះ បានជាមនុស្សប្រុសនឹងលាចេញពីឪពុកម្តាយខ្លួន ទៅនៅជាប់នឹងប្រពន្ធវិញ ហើយអ្នកទាំង២នោះនឹងត្រឡប់ជាសាច់តែ១សុទ្ធ»។

ការចងស្ពានមេត្រីដ៏អស្ចារ្យរវាងមនុស្សប្រុសនិងមនុស្សស្រី គឺជាចំណុចស្នូលនៃគ្រួសារតាមព្រះតម្រិះចេញពីព្រះជាម្ចាស់។ ប្រសិនបើស្ពានមេត្រីនេះមានការបាក់បែកដោយប្រការណាមួយដូចជា ការទទួលមរណភាព ឬក៏ការលែងលះគ្នា ពេលនោះនឹងមានម្នាក់ត្រូវចិញ្ចឹមកូនៗតែឯងហើយ។ ព្រះជាម្ចាស់ស្មោះត្រង់ចំពោះឪពុកម្តាយជាច្រើនលាននាក់ដែលពួកគាត់បានចិញ្ចឹមកូនៗតែម្នាក់ឯង។ ប៉ុន្តែបំណងព្រះហឫទ័យដំបូងរបស់ព្រះជាម្ចាស់ចំពោះគ្រួសារ គឺឲ្យបុរសម្នាក់ និងស្ត្រីម្នាក់បាននៅជាប់ជាមួយគ្នា ហើយត្រឡប់ជាសាច់តែមួយសុទ្ធដោយធ្វើជាប្តីនិងប្រពន្ធ ហើយបង្កើតកូនចៅ។ តាមរយៈការនេះព្រះជាម្ចាស់ចង់ឃើញ ប្តីនិងប្រពន្ធបង្កើតកូនក្នុងរូបអង្គទ្រង់ឲ្យបានពេញពាសលើផែនដី ហើយឲ្យពួកគេឆ្លុះបញ្ចាំងពីសិរីល្អរបស់ទ្រង់។ ព្រះជាម្ចាស់ក៏សព្វព្រះហឫទ័យឲ្យគូស្វាមីភរិយាបង្ហាញដល់លោកីយ៍ពីស្ពានមេត្រីរវាងគ្នា

នឹងគ្នាដែលថា ទ្រង់មានទំនាក់ទំនងជាមួយរាស្ត្រទ្រង់ដោយក្ដីស្រឡាញ់ និងភាពស្មោះត្រង់តាមរយៈការតាំងសញ្ញារបស់ទ្រង់។

ការបង្កើតឲ្យមានគ្រួសារ គឺជាព្រះតម្រិះរបស់ព្រះជាម្ចាស់ ហើយក៏ដើម្បីសិរីល្អរបស់ទ្រង់ដែរ។ ស្ដេច សាឡូម៉ូន បានសន្និដ្ឋានពីការនេះក្នុងកណ្ឌគម្ពីរ សុភាសិត ១:៧-៩។

## ២. គ្រួសារគឺជាសាលារៀន

គ្រួសារគឺជាសាលារៀនមូលដ្ឋានដែលព្រះជាម្ចាស់បង្កើតមកសម្រាប់បង្រៀនកូនៗឲ្យចេះរស់នៅបានត្រឹមត្រូវក្នុងលោកីយ៍នេះ។

សូមអានកណ្ឌគម្ពីរ សុភាសិត ១:៨ ម្ដងទៀតដែលចែងថា «នែ កូនអើយ ចូរស្ដាប់ពាក្យប្រៀនប្រដៅរបស់ឪពុកចុះ កុំឲ្យកូនបោះបង់ចោលសេចក្ដីដំបូន្មានរបស់ម្ដាយឯងឡើយ»។ ឪពុកគឺជាអ្នកប្រៀនប្រដៅ ហើយម្ដាយគឺជាអ្នកទូន្មាន។ ហេតុដូច្នេះហើយបានជាយើងរាប់ថា គ្រួសារគឺជាសាលារៀន។

ព្រះជាម្ចាស់មិនគ្រាន់តែសព្វព្រះហឫទ័យឲ្យគ្រួសារបង្កើតកូនចៅពេញពាសផែនដីប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏សព្វព្រះហឫទ័យឲ្យពួកគេចេញទៅដោយបានទទួលការបង្ហាត់បង្រៀនជាមុនដែរ។ គ្រួសារគឺជាកន្លែងដែលបង្កើតក្មេងៗជំនាន់ក្រោយ ហើយក៏ជាកន្លែងដែលកូនៗរៀនឲ្យចេះពីរបៀបនៃការរស់នៅផងដែរ។

ពេលយើងកើតមក យើងមិនទាន់ចេះពីរបៀបនៃការរស់នៅ នៅឡើយទេ។ ដូច្នេះ យើងត្រូវរៀនគ្រប់របៀបនៃការរស់នៅ ទោះទាំងការដេក ដើរ ឈរ អង្គុយ ការនិយាយស្ដី និងរបៀបហូបចុក ក៏ដូចជាការមានសុជីវធម៌ ការចេះអរគុណ ចេះគោរព និងជំនឿលើព្រះគ្រីស្ទជាដើម។

គ្រួសារគឺជាសាលារៀនដែលព្រះជាម្ចាស់បង្កើតមកសម្រាប់បង្រៀនក្មេងៗជំនាន់ក្រោយឲ្យចេះរស់នៅក្នុងលោកីយ៍នេះ និងឲ្យចេះត្រៀមខ្លួនជាស្រេចសម្រាប់ជីវិតអស់កល្បជានិច្ចនៅស្ថានសួគ៌។

ហើយទោះបើឪពុកម្ដាយរកអ្នកផ្សេងៗដូចជាសាច់ញាតិ មេដោះ កន្លែងមើលក្មេង សាលាថ្ងៃអាទិត្យ សាលាបឋមសិក្សា និងសាលាអនុវិទ្យាល័យឲ្យមកជួយមើលថែកូនៗរបស់ពួកគេយ៉ាងណាក៏ដោយ ក៏ទំនួលខុសត្រូវក៏នៅតែធ្លាក់លើឪពុកម្ដាយដដែល។ ទីបញ្ចប់ យើងដែលជាឪពុកម្ដាយនឹងត្រូវរៀបរាប់ពីរបៀបដែលយើងបានបណ្ដោយឲ្យអ្នកដទៃបត់បែនចិត្តគំនិតកូនៗរបស់យើងចំពោះព្រះជាម្ចាស់។

ចំណុចទីពីរ៖ គ្រួសារគឺជាសាលារៀនដែលព្រះជាម្ចាស់បង្កើត ដើម្បីបង្រៀនកូនៗឲ្យចេះរស់នៅក្នុងលោកីយ៍នេះ។

## ៣. សេចក្តីកោតខ្លាចដល់ព្រះជាម្ចាស់ជាប្រធានបទស្នូល

សេចក្តីកោតខ្លាចដល់ព្រះជាម្ចាស់គឺជាមូលដ្ឋានគ្រឹះរបស់ក្រុមគ្រួសារ។

កណ្ឌគម្ពីរ សុភាសិត ១:៧ បានចែងថា «សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាដើមចមនៃដំរិះ»។ និយាយម្យ៉ាងវិញទៀត ប្រសិនបើយើងសួរថា តើអ្វីទៅជាមូលដ្ឋានគ្រឹះ ជាដើមចម ឬជាប្រធានបទស្នូលនៃសេចក្តីបង្រៀនរបស់ឳពុកម្តាយ? តើឳពុកម្តាយយកអ្វីមកធ្វើជាគំរូ មកពន្យល់ មកកែតម្រូវ ឬមកដាក់វិន័យ ដើម្បីឲ្យអ្វីៗដែលកូនៗធ្វើនោះមានខ្លឹមសារ? ចម្លើយគឺ៖ សេចក្តីកោតខ្លាចដល់ព្រះជាម្ចាស់។

គ្រួសារមិនគ្រាន់តែជាកន្លែងសម្រាប់បង្រៀនឲ្យកូនៗចេះកាន់ស្លាបព្រា ចេះដើរ ចេះចងខ្សែស្បែកជើង ឬក៏ចេះនិយាយថា «អរគុណ» ប៉ុណ្ណោះទេ។ ប្រាកដណាស់ដែលថា គ្រួសារជាកន្លែងដែលការទាំងអស់នោះត្រូវចាប់ផ្តើម ជាមួយព្រះជាម្ចាស់ តាមព្រះបន្ទូលរបស់ទ្រង់ ដើម្បីឆ្លុះបញ្ចាំងពីសិរីល្អរបស់ព្រះជាម្ចាស់ដែរ។ ព្រះជាម្ចាស់បង្កើតគ្រួសារមក ដើម្បីឲ្យយើងចេះគោរពកោតខ្លាចទ្រង់។ ការកោតខ្លាចដល់ព្រះជាម្ចាស់មានន័យថា ការគោរពទ្រង់ ការឈរដោយស្ញប់ស្ញែងចំពោះទ្រង់ និងការទុកចិត្តលើទ្រង់។

ការបង្កើតឲ្យមានគ្រួសារគឺជាព្រះតម្រិះរបស់ព្រះជាម្ចាស់។ គ្រួសារគឺជាសាលារៀន ហើយព្រះជាម្ចាស់ជាប្រធានបទស្នូលក្នុងសាលារៀននោះ។

## ៤. ទំនួលខុសត្រូវរបស់លោកឳពុកអ្នកម្តាយ

នៅពីក្រោមការគ្រប់គ្រងរបស់ព្រះជាម្ចាស់មានឳពុកម្តាយដែលចាំមើលការខុសត្រូវក្នុងការបង្ហាត់បង្រៀនកូនៗរបស់ខ្លួន។

កណ្ឌគម្ពីរ សុភាសិត ១:៨ ចែងថា «នែ កូនអើយ ចូរស្តាប់ពាក្យប្រៀនប្រដៅរបស់ឳពុកចុះ កុំឲ្យកូនបោះបង់ចោលសេចក្តីដំបូន្មានរបស់ម្តាយឯងឡើយ»។

ខគម្ពីរនេះមិនបានលើកឡើងថា «ឳពុកគឺជាអ្នកប្រៀនប្រដៅ *ហើយម្តាយជាអ្នកផ្លាស់ខោទឹកនោម*» ទេ។ ហើយក៏មិនបានលើកឡើងដែរថា «*ដោយសារឳពុកជាអ្នករកស៊ី* ដូច្នោះគាត់មិនចាំបាច់មានតួនាទីក្នុងការបង្ហាត់បង្រៀនកូនៗនោះទេ»។ ហើយក៏មិនដែលលើកឡើងដែរថា «*ដោយសារម្តាយចេញទៅរកស៊ី* ដូច្នោះគាត់អាចឲ្យមេដោះមកមើលការខុសត្រូវជំនួសគាត់» បាននោះដែរ។ ផ្ទុយទៅវិញ ខគម្ពីរនេះបានលើកឡើងថា ឳពុកគឺជាអ្នកប្រៀនប្រដៅ ហើយម្តាយគឺជាអ្នកទូន្មាន។ សរុបមក លោកទាំងពីរគឺជាអ្នកមានទំនួលខុសត្រូវក្នុងការបង្ហាត់បង្រៀនកូនៗ។

ខាងក្រោមនេះគឺជាឧទាហរណ៍ដ៏ល្អមួយដែលដកស្រង់ចេញពីព្រះគម្ពីរសញ្ញាថ្មី៖ ឥទ្ធិពលម្ដាយ និងយាយរបស់លោក ធីម៉ូថេ។

សាវ័ក ប៉ុល បានសរសេរនៅក្នុងកណ្ឌគម្ពីរ ២ធីម៉ូថេ ១:៥ ថា៖

«ដ្បិតខ្ញុំនឹកចាំពីសេចក្ដីជំនឿស្មោះត្រង់ ដែលនៅក្នុងអ្នក សេចក្ដីជំនឿនោះបាននៅក្នុងយាយឡូអ៊ីស ជាជីដូនរបស់អ្នក ជាមុនដំបូង រួចក៏នៅក្នុងអ្នកអើនីស ជាម្ដាយអ្នកដែរ ហើយខ្ញុំជឿជាក់ថា ក៏នៅក្នុងអ្នកផង»។

សាវ័ក ប៉ុល បានសរសេរថែមទៀតនៅក្នុងកណ្ឌគម្ពីរ ២ធីម៉ូថេ ៣:១៤-១៥ ថា៖

«តែឯអ្នក ចូរឲ្យអ្នកនៅជាប់ក្នុងសេចក្ដីដែលអ្នកបានរៀន ហើយជឿប្រាកដវិញ ដោយដឹងថា អ្នកបានរៀនសេចក្ដីនោះពីអ្នកណា ហើយថា តាំងពីក្មេងតូចមក អ្នកបានស្គាល់បទគម្ពីរទាំងប៉ុន្មាន ដែលអាចនឹងនាំឲ្យអ្នកមានប្រាជ្ញាដល់ទីសង្គ្រោះ ដែលបានដោយសារសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទយេស៊ូវផង»។

នេះគឺជាទីបន្ទាល់ដ៏អស្ចារ្យដែលគួរឲ្យកត់សម្គាល់! ឪពុករបស់ធីម៉ូថេជាសាសន៍ក្រិក (កិច្ចការ ១៦:៣)។ ឪពុកគាត់ប្រហែលមិនស្គាល់ព្រះបន្ទូលទេ។ ហេតុដូច្នោះហើយបានជាសាវ័ក ប៉ុល សរសើរពីកេរ្ដិ៍ដំណែលរបស់ធីម៉ូថេតាមខ្សែស្រឡាយខាងម្ដាយ និងយាយរបស់គាត់វិញ។ ម្ដាយ និងយាយរបស់គាត់បានធ្វើអ្វីដែលឪពុករបស់គាត់មិនចេះធ្វើ ឬមិនព្រមធ្វើ។ ពួកគាត់បានបណ្ដុះបណ្ដាលព្រះបន្ទូលរបស់ព្រះជាម្ចាស់ដល់ធីម៉ូថេ ហើយតាមរយៈការនោះព្រះបន្ទូលបាននាំឲ្យគាត់ជឿលើព្រះគ្រីស្ទ ដែលជាហេតុបណ្ដាលឲ្យគាត់ទទួលបានសេចក្ដីសង្គ្រោះរបស់ព្រះគ្រីស្ទដែរ។

លោក ធីម៉ូថេ នឹងមានជីវិតអស់កល្បជានិច្ច ព្រោះម្ដាយនិងយាយរបស់គាត់ស្មោះត្រង់ក្នុងការត្រាប់តាមកណ្ឌគម្ពីរសុភាសិត ១:៨។

## ៥. កូនៗដែលចេះចុះចូល

ព្រះជាម្ចាស់បានបង្គាប់ឲ្យកូនៗឲ្យចេះចុះចូលចំពោះឪពុកម្ដាយរបស់ខ្លួន។

កណ្ឌគម្ពីរ សុភាសិត ១:៨ បានចែងថា «នែ កូនអើយ ចូរស្ដាប់ពាក្យប្រៀនប្រដៅរបស់ឪពុកចុះ កុំឲ្យកូនបោះបង់ចោលសេចក្ដីដំបូន្មានរបស់ម្ដាយឯងឡើយ»។

បញ្ញត្តិទាំងពីរនេះក្រើនរំឭកកុំឲ្យកូនៗធ្លាក់ទៅក្នុងការល្បួងនៃការបះបោរពីរយ៉ាង។ ការល្បួងទីមួយគឺនៅពេលកូននៅក្នុងផ្ទះ ហើយការល្បួងទីពីរគឺនៅពេលកូនរស់នៅបែកផ្ទះ។ ប្រសិនបើកូននោះនៅផ្ទះ ការល្បួងនៃការបះបោរគឺ ការមិនស្ដាប់ដំបូន្មានឪពុកម្ដាយ។ ហេតុដូច្នោះហើយបានជាស្ដេច សាឡូម៉ូន សរសេរថា «ចូរស្ដាប់ពាក្យប្រៀនប្រដៅរបស់ឪពុក»។ ប្រសិនបើកូនរស់នៅបែកផ្ទះ ការល្បួងនៃការបះបោរគឺ ការបោះបង់នូវអ្វីដែលឪពុកម្ដាយបានបង្រៀនទាំងអម្បាលម៉ានចោល។ ហេតុដូច្នោះហើយបានជាស្ដេច សាឡូម៉ូន សរសេរថា «កុំឲ្យកូនបោះបង់ចោលសេចក្ដីដំបូន្មានរបស់ម្ដាយឯងឡើយ»។

មនុស្សវ័យក្មេងអើយ! ចូរស្ដាប់ឪពុកម្ដាយនៅពេលឯងនៅផ្ទះ។ កុំឲ្យបដិសេធ ឬមិនយកចិត្តទុកដាក់នូវអ្វីៗដែលឪពុកម្ដាយបានបង្រៀនឡើយ។ ចូរស្ដាប់ឪពុកម្ដាយដោយយល់ដល់ព្រះនាមរបស់ព្រះជាម្ចាស់ចុះ។ ការស្ដាប់បង្គាប់ឪពុកម្ដាយមានសំខាន់ណាស់នៅចំពោះព្រះនេត្រព្រះជាម្ចាស់ ហេតុដូច្នោះហើយបានជាទ្រង់បូករួមបញ្ចូលវាទៅក្នុងបញ្ញត្តិទាំងដប់ប្រការដែលបញ្ញត្តិនេះសង្ខេបក្រឹត្យវិន័យទាំងអស់។ កណ្ឌគម្ពីរ និក្ខមនំ ២០:១២ បានចែងថា «ចូរឲ្យគោរពប្រតិបត្តិដល់ឪពុកម្ដាយ»។ ចូរគោរពប្រតិបត្តិដល់ឪពុកដោយស្ដាប់គាត់ពេលដែលគាត់និយាយ។ ចូរគោរពប្រតិបត្តិដល់ម្ដាយឯងដោយចងចាំនូវអ្វីៗដែលគាត់បានបង្រៀនឯងអំពីការខុសត្រូវ ល្អអាក្រក់ ពីការកោតខ្លាចដល់ព្រះជាម្ចាស់ ក្នុងកាលដែលឯងនៅបែកផ្ទះនឹងគាត់ ហើយក្នុងកាលដែលមិនមានអ្នកណាម្នាក់ឃើញទង្វើឯងប្រព្រឹត្តិបែបយ៉ាងណា លើកលែងតែឯង និងព្រះជាម្ចាស់ដែលមើលឃើញប៉ុណ្ណោះ។

## ៦. សេចក្ដីសន្យាពីរង្វាន់

សរុបសេចក្ដីមក ព្រះជាម្ចាស់រៀបចំរង្វាន់សម្រាប់កូនប្រុសស្រីណាដែលមិនបោះបង់ដំបូន្មានរបស់ឪពុកម្ដាយខ្លួន នេះបើយោងតាមកណ្ឌគម្ពីរ សុភាសិត ១:៩៖

«ដ្បិតសេចក្ដីនោះនឹងបានជាគុណពាក់លើក្បាលឯង ទុកជាគ្រឿងលំអ ហើយជាខ្សែប្រដាប់ពាក់នៅកឯង»។

ខគម្ពីរនេះបញ្ជាក់ថា ការប្រៀនប្រដៅរបស់ឪពុក និងដំបូន្មានរបស់ម្ដាយដែលកោតខ្លាចដល់ព្រះគឺជាអត្ថប្រយោជន៍ដល់កូនៗ។ កូនៗភាគច្រើនមិនយល់ពីអត្ថប្រយោជន៍នេះទេ។ ហើយពេលខ្លះ ឪពុកម្ដាយដែលមិនបានទទួលការចិញ្ចឹមបីបាច់ថែរក្សាបង្ហាត់បង្រៀននៅក្នុងព្រះគុណក៏មិនយល់ពីអត្ថប្រយោជន៍នេះដែរ។ ទោះជាយ៉ាងណាក្ដី ខគម្ពីរនេះនៅតែបញ្ជាក់ដដែលថា៖ ការស្ដាប់ពាក្យប្រៀនប្រដៅរបស់ឪពុក និងការមិនបោះបង់ចោលដំបូន្មានរបស់ម្ដាយនឹងនាំឲ្យកូនៗមានគុណ សិរីល្អ និងការអរសប្បាយដូចជាគ្រឿងលម្អលើក្បាលពួកគេ ក៏ដូចជាខ្សែប្រដាប់ពាក់នៅករបស់ពួកគេដែរ។ ក្នុងន័យម្យ៉ាងទៀត ខគម្ពីរនេះក៏មានន័យដែរថា កូនៗនឹងមានជ័យជម្នះ ភាពសប្បាយរីករាយ និងអំណរ។

សាវ័ក ប៉ុល បានសរសេរនៅកណ្ឌគម្ពីរ អេភេសូរ ៦:២ ថា «ចូរគោរពប្រតិបត្តិដល់មាតាបិតាខ្លួន នេះជាបញ្ញត្តិមុនដំបូងដែលជាប់មានទាំងសេចក្ដីសន្យាផង»។ ខគម្ពីរនេះបានចែងយ៉ាងច្បាស់ថា ការគោរពប្រតិបត្តិដល់ឪពុកម្ដាយ និងការ

ឱបក្រសោបការកោតខ្លាចដល់ព្រះជាម្ចាស់ដូចដែលពួកគេបានបង្រៀនពិតជាមានសេចក្តីសន្យាដ៏អស្ចារ្យមែន។

- «មនុស្សដែលកោតខ្លាចដល់ព្រះយេហូវ៉ា នោះមានទីពឹងមាំមួន...សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជារន្ធទឹកនៃជីវិត» (សុភាសិត ១៤:២៦-២៧)។
- «សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះប្រោសឲ្យមានជីវិត ហើយអ្នកណាដែលមានសេចក្តីនោះនឹងនៅតែមានចិត្តស្កប់ស្កល់ជានិច្ច ឥតមានសេចក្តីអាក្រក់ណាមកលើខ្លួនឡើយ» (សុភាសិត ១៩:២៣)។

រង្វាន់នៃការឱបក្រសោបការកោតខ្លាចដល់ព្រះជាម្ចាស់ដែលឪពុកម្តាយបានបង្រៀនគឺ កូនៗនឹងទទួលបានរន្ធទឹកនៃជីវិត ទីពឹងមាំមួន និងការមានចិត្តស្កប់ស្កល់ជានិច្ចទុកជាគ្រឿងលម្អ ហើយជាខ្សែប្រដាប់ពាក់នៅករបស់ពួកគេ។

**មកុដនៃក្តីអំណររបស់អ្នកម្តាយ**

ដោយសារថ្ងៃនេះជាថ្ងៃសម្តែងការគោរពដឹងគុណដល់ម្តាយ (Mother's Day) ជាការល្អប្រសិនបើយើងបញ្ចប់អត្ថបទនេះដោយរំឭកខ្លួនឯងក្នុងនាមជាកូនប្រុសស្រី ទោះបើក្មេងឬចាស់ថា ការទទួលបានរន្ធទឹកនៃជីវិត ទីពឹងមាំមួន និងការមានចិត្តស្កប់ស្កល់ជានិច្ច គឺកើតឡើងតាមរយៈការគោរពប្រតិបត្តិតាមគ្រប់សេចក្តីពិតដែលម្តាយយើងបានបង្រៀនយើង ហើយការដែលយើងធ្វើបែបនោះក៏នឹងក្លាយជាមកុដនៃក្តីអំណរ ការគោរព និងជាពរដល់គាត់ដែរនៅពេលគាត់ចាស់ជរា។ កណ្ឌគម្ពីរ សុភាសិត ២៣:២២ បានចែងថា «...កុំឲ្យមើលងាយម្តាយឯងក្នុងកាលដែលគាត់ចាស់ឡើយ»។ ខ២៥ ក៏ចែងដែរថា «...ដូច្នេះ ចូរបើកឱកាសឲ្យឪពុកម្តាយឯងបានរីករាយចុះ ហើយឲ្យអ្នកដែលសំរាលឯងមកនោះមានចិត្តសប្បាយផង»។ កុំឲ្យបោះបង់ដំបូន្មានរបស់ម្តាយឯងចោលឡើយ។ ដ្បិតសេចក្តីនោះនឹងបានជាគុណពាក់លើក្បាលឯង ព្រមទាំងក្លាយជាមកុដនៃក្តីអំណរដល់គាត់ផងដែរ។